# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

## ការបង្កើតតំបន់ព្រៃការពារអភិរក្សដីជំរាល ជួរភ្នំក្រវាញភាគកណ្តាល និង ជីវៈចំរុះ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៩/០៧ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឱ្យមានការកំណត់ និងការគ្រប់គ្រងព្រៃតំបន់ដីជំរាលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-បានឃើញក្រឹត្យ-ច្បាប់លេខ ៣៥ ក្រ.ច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០២

www.pheakdeylaw.com

# ស ំ រេ ច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតតំបន់ព្រៃការពារអភិរក្សជីវចម្រុះជីវភាពជួរភ្នំក្រវាញភាគកណ្តាល និង ជីវៈចំរុះ ស្ថិតក្នុងខេត្តកោះកុង ពោធិ៍សាត់ និង កំពង់ស្ពឺ ក្នុងគោលបំណង÷

-ការពារ និង អភិរក្សរុក្ខជាតិ និង សត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទដែលកំពុងទទួលរងគ្រោះ និង ប្រភេទជិតផុតពូជ

-រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាទីជំរកសំរាប់ការស្នាក់អាស្រ័យ និង ការបន្តពូជរបស់ប្រភេទសត្វព្រៃ

-សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ដើម្បីអភិវឌ្ឍ និង អភិរក្សជីវភាព និង ជីវៈចំរុះ

-ការពារការហូរច្រោះ ទឹកជំនន់ រក្សានូវសុក្រឹតភាពនៃប្រភពទឹក និង គុណភាពទឹក ទប់ទល់ការបាត់បង់ជីជាតិរបស់ដី

-ជំរុញការអប់រំ ផ្សព្វផ្សាយ និង អភិវឌ្ឍសហគមន៍

-ថែរក្សា និង អភិវឌ្ឍវិស័យទេសចរធម្មជាតិ

-ថែរក្សានូវកេរ្តិ៍តំណែលវប្បធម៌ប្រវត្តិសាស្ត្រ ដែលមាននៅក្នុងតំបន់ ។

**មាត្រា ២.-**

-តំបន់ព្រៃការពារអភិរក្សជីវភាពជួរភ្នំក្រវាញភាគកណ្តាល និង ជីវៈចំរុះ មានផ្ទៃក្រឡា ៤០១.៣១៣ហិកតា ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ ជាប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកៈ A(302658, 1330480), B(311761, 1301421), C(318825, 1300521), D(325414, 1295388), E(326736, 1294568), F(326392, 1290679), G(344602, 1304649), H(346038, 1306077), I(347281, 1304463), J(350582, 1301355), K(340987, 1286035), L(344554, 1286035), M(351233, 1286035), N(358932, 1276257), O(367052, 1277948), P(371870, 1284576), Q(377272, 1288840), R(375178, 1292106), S(374993, 1308969), T(370710, 1334652), U(368848, 1332530), V(365227, 1333316), W(362431, 1334229), X(359046, 1329176), Y(356436, 1328638), Z(355184, 1338751), A1(349193, 1340494), B1(348154, 1342182), C1(347646, 1347148), D1(346657, 1349221), E1(344812, 1351941), F1(344553, 1353014), G1(344254, 1355442), H1(343192, 1359674), I1(309854, 1358599) ។

-ផ្ទៃក្រឡាតំបន់ព្រៃការពារអភិរក្សជីវភាពជួរភ្នំក្រវាញភាគកណ្តាល និង ជីវៈចំរុះ អាចធ្វើការកែប្រែតាមការចាំបាច់ដោយផ្អែកលើពត៌មានវិទ្យាសាស្ត្រ និង ស្ថានភាពជាក់ស្តែង ។ ការកែប្រែនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី២
## វិសាលភាព

**មាត្រា ៣.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវធ្វើការរៀបចំ និង គ្រប់គ្រងតំបន់ព្រៃការពារអភិរក្សជីវភាព

www.pheakdeylaw.com

ជួរភ្នំក្រវាញភាគកណ្តាល និង ជីវៈចំរុះ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីធានានូវការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយនិរន្តរភាព សំរាប់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់នោះ ។

# ជំពូកទី៣

# ភារកិច្ច

**មាត្រា ៤.-**

ដំណើរការនៃការរៀបចំ និង ការគ្រប់គ្រងតំបន់ព្រៃការពារអភិរក្សជីជំរាលជួរភ្នំក្រវាញភាគកណ្តាល និង ជីវៈចំរុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

# ជំពូកទី៤

# អវសានប្បញ្ញត្តិ

**មាត្រា ៥.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្តកោះកុង អភិបាលខេត្តពោធិសាត់ និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តនីអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៦
- ឯកសារ -កាលប្បវត្តិ

www.pheakdeylaw.com